**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាអគ្គសញ្ញាអាពាហ៍ពិពាហ៍**
**ភ្នំពេញថ្មី ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៩**

# បង្កើតគ្រួសារដ៏សុខសាន្ត

**អត្ថបទទី១៖ កំណើតពិភពលោក ១,២៦-២៨**

ព្រះជាម្ចាស់បានប្រទានពរឲ្យគេ គឺព្រះអង្គមានព្រះបន្ទូលថា៖ «ចូរបង្កើតកូនចៅឲ្យបានកើនច្រើនឡើងពាសពេញលើផែនដី ហើយត្រួតត្រាផែនដីទៅ។ ចូរមានអំណាចលើត្រីសមុទ្រ លើបក្សាបក្សីដែលហើរនៅលើមេឃ និងលើសត្វទាំងប៉ុន្មាន ដែលលូនវារនៅលើដី»។ កណ ១,២៨

**ដំណឹងល្អ៖ ម៉ាថាយ ៥,១៣-១៦**

ចូរឲ្យពន្លឺរបស់អ្នករាល់គ្នា បំភ្លឺមនុស្សទាំងឡាយដូច្នោះដែរ គេនឹងឃើញអំពើល្អដែលអ្នករាល់គ្នាប្រព្រឹត្ត ហើយលើកតម្កើងសិរីរុងរឿងព្រះបិតារបស់អ្នករាល់គ្នា ដែលគង់នៅស្ថានបរមសុខ។ មថ ៥,១៦

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងសប្បាយចិត្តដោយសារទាំងពីរនាក់ មានម្នាក់ជាពុទ្ធបរិស័ទនិងម្នាក់ទៀតជាគ្រីស្តបរិស័ទបានឯកភាពទទួលអគ្គសញ្ញាអាពាហ៍ពិពាហ៍នៅក្នុងព្រះសហគមន៍។ ជាពេលវេលាមួយ ដើម្បីគិតអំពីអនាគតយ៉ាងពិសេសដោយកសាងគ្រួសារថ្មី យើងទទួលសញ្ញាមួយពិសេសគឺជាសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ដែលយាងចូលនៅក្នុងប្អូនទាំងពីរនាក់ដើម្បីធ្វើដំណើរទៅមុខទៀត។ **តើយើងមានគម្រោងការអ្វីខ្លះសម្រាប់អនាគតយើង?** ខ្ញុំមានចំណុចពីរដើម្បីរិះគិត៖

ទីមួយ សូមនឹកឃើញអ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូល "**សូមបន្តពូជបង្កើតកូនចៅ**" នេះជាអ្វីដែលព្រះជាម្ចាស់បានណែនាំអាដាំនិងអេវ៉ាពីដើម។ ដូច្នេះ ពេលយើងគិតអំពីអនាគតយើង យើងត្រូវការគិតអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ប្រសិនបើអាដាំនិងអេវ៉ាមិនបានបន្តពូជសព្វថ្ងៃយើងមិនអាចអង្គុយនៅទីនេះទេ។ ឪពុកម្តាយបានសប្បាយចិត្ត ដោយសារកូនបានរៀបការនិងបន្តពូជ។

ទីពីរ "**សូមត្រួតត្រាផែនដី**" យកចិត្តទុកដាក់ ទទួលខុសត្រូវលើផែនដី មានន័យថាផែនដីដែលយើងបានទទួលជាអំណោយរបស់ព្រះជាម្ចាស់។ អ្វីៗទាំងអស់ដែលមាននៅលើផែនដីនេះ យើងត្រូវការទទួលខុសត្រូវយ៉ាងខ្ពស់។ សម្រាប់លោកបូជាចារ្យ គាត់មិនអាចយកប្រពន្ធនិងបន្ត

ពូជបានទេ តែយើងមានកូនចៅច្រើនដែលជាគ្រីស្តបរិស័ទដែលបានទទួលអគ្គសញ្ញាជ្រមុជជាមួយយើង។

គម្រោងការរបស់យើងនៅយូរណាស់ ហើយមានកាលៈទេសៈច្រើននៅក្នុងជីវិត សំខាន់សម្រាប់យើងជាប្តីប្រពន្ធយូរៗម្តង យើងអង្គុយដើម្បីនិយាយគ្នាអំពីជីវិត អំពីអនាគត អំពីអំណរសប្បាយ អំពីសេចក្តីសង្ឃឹមសម្រាប់គ្រួសារយើង...។ ឲ្យយើងយកពេលវេលា ដើម្បីកសាងជីវិតជាប្តីប្រពន្ធ ប្រសិនបើយើងមិនយកពេលវេលាដើម្បីនិយាយគ្នាយូរៗយើងនៅឆ្ងាយពីគ្នា។ ម្យ៉ាងទៀត ឲ្យយើងយកចិត្តទុកដាក់ទៅជាមនុស្សសកម្ម គ្រីស្តបរិស័ទសកម្ម ប្តីប្រពន្ធសកម្ម ដែលចូលនៅក្នុងគ្រប់វិស័យនៃជីវិត យើងជាប្តីប្រពន្ធយើងមានគ្រួសារយើងដ៏ពិសេស យើងមានកូនយើងយកចិត្តទុកដាក់ យើងចូលនៅក្នុងសង្គមតាមរយៈអ្នកជិតខាង ឲ្យយើងធ្វើជាមនុស្សសកម្ម។ ម្យ៉ាងវិញ ខ្ញុំបានឃើញត្រីឆ្លាមខ្មែរដែលហែរហូតមិនដែលសម្រាក់ ជាប់នឹងត្រីឆ្លាមនេះមានកង្កែបតណ្ហានេស៊ីមិនដែលធ្វើសោះ ដូច្នេះសម្រាបយើង **តើយើងជាឆ្លាមយ៉ាងសកម្ម ឬយើងជាកង្កែបមហាខ្ជិល?** ឲ្យយើងទៅជាប្តីប្រពន្ធសកម្មដែលចេះស្រឡាញ់ ដែលចេះគោរពគ្នា ដែលចេះស្តាប់គ្នាទៅវិញទៅមក ជាពិសេសដែលចូលនៅក្នុងអ្វីៗទាំងអស់ដែលមាននៅក្នុងសង្គមដើម្បីឲ្យយើងទៅជាមនុស្សដែលពោរពេញដោយវិញ្ញាណមកពីព្រះជាម្ចាស់។ ព្រះវិញ្ញាណដ៏វិសុទ្ធ ជាវិញ្ញាណដែលណែនាំឲ្យយើងមានយោបល់ល្អ ដឹងខុសដឹងត្រូវ មានសេចក្តីក្លាហានដើម្បីកសាងជីវិត។

សូមព្រះជាម្ចាស់ប្រទានពរសម្រាប់ចន្ថា និងស្រីតូច ដើម្បីមានសេចក្តីក្លាហាន ដើម្បីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់យាងចូលយ៉ាងពេញលក្ខណៈ ឲ្យយើងធ្វើជាប្តីប្រពន្ធនិងបង្កើតគ្រួសារដ៏សុខសាន្ត ដែលណែនាំឲ្យយើងមានសង្គមយ៉ាងសុខសាន្ត និងព្រះសហគមន៍យ៉ាងសុខសាន្តដែរ។ អាម៉ែន៕